# សំណួរសួរញឹកញាប់អំពីអាជីវកម្មប្រភេទទ្រទ្រង់ជីវិត

1. **តើខ្ញុំអាចកំណត់យ៉ាងដូចម្តេចថាតើអាជីវកម្មរបស់ខ្ញុំត្រូវបានចាត់ទុកថាជាអាជីវកម្មប្រភេទទ្រង់ទ្រង់ជីវិត ហើយត្រូវបានអនុញ្ញាតឱ្យបន្តប្រតិបត្តិការដោយផ្ទាល់ និងប្រតិបត្តិការនៅទីតាំងជាក់ស្តែង?**

   បណ្តាអាជីវកម្មគួរតែពិនិត្យមើលបទបញ្ជារបស់អភិបាល ជាមុនសិន និងបញ្ជីឈ្មោះអាជីវកម្មប្រភេទទ្រទ្រង់ជីវិតដែលមាននៅទីនេះ។ បញ្ជីនេះត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឱ្យស្របតាមការណែនាំស្តីពីហេដ្ឋារចនាសម្ព័ន្ធសំខាន់ចាំបាច់ ដែលចេញដោយទីភ្នាក់ងារសន្តិសុខលើបណ្តាញអ៊ីនធឺណិត និងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធនៃក្រសួងសន្តិសុខមាតុភូមិ។

   ក្រោយពីបានពិនិត្យមើលបទបញ្ជា និងពិនិត្យមើលសេចក្តីណែនាំរបស់ទីភ្នាក់ងារសន្តិសុខលើបណ្តាញអ៊ីនធឺណិត និងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធនៃក្រសួងសន្តិសុខមាតុភូមិ ប្រសិនបើចម្លើយនៅតែមិនច្បាស់ទៀត ក្រុមហ៊ុនអាជីវកម្មអាចផ្ញើអ៊ីមែលទៅក្រសួងអភិវឌ្ឍន៍សហគមន៍ និងសេដ្ឋកិច្ច (DCED) ដើម្បីសុំជំនួយបន្ថែមតាមគណនីអ៊ីមែលខាងក្រោម។ ការសាកសួរព័ត៌មាននឹងត្រូវឆ្លើយតបយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន៖ ra-dcedcs@pa.gov។

2. **តើអ្នកណាត្រូវការការលើកលែង?**

   អាជីវកម្មណាដែលមិនមានការអនុញ្ញាតឱ្យរក្សាប្រតិបត្តិការនៅទីតាំងជាក់ស្តែងយោងតាមបញ្ជី និងសេចក្តីណែនាំរបស់ទីភ្នាក់ងារសន្តិសុខលើបណ្តាញអ៊ីនធិណិត និងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធនៃក្រសួងសន្តិសុខមាតុភូមិ គួរតែដាក់ពាក្យសុំការលើកលែង។

3. **តើអាជីវកម្មត្រូវបានអនុញ្ញាតឱ្យបន្តប្រតិបត្តិការដោយផ្ទាល់នៅទីតាំងជាក់ស្តែងដែរឬទេនៅពេលកំពុងដាក់ពាក្យសុំការលើកលែង?**

   អាជីវកម្មដែលស្វែងរកការលើកលែងគួរតែអនុវត្តតាមបទបញ្ជារបស់អភិបាល និងផ្អាកប្រតិបត្តិការដោយផ្ទាល់នៅទីតាំងជាក់ស្តែងរហូតដល់ការលើកលែងត្រូវបានអនុម័ត និងផ្តល់ជូន។

4. **តើអាជីវកម្មត្រូវស្នើសុំការលើកលែងយ៉ាងដូចម្តេច?**

   វិធីដែលស្រួលបំផុត និងរហ័សបំផុតក្នុងការដាក់ស្នើសុំការលើកលែងគឺត្រូវ បំពេញពាក្យសុំការលើកលែងរបស់ DCED ហើយផ្ញើពាក្យនេះទៅ Ra-dcexemption@pa.gov ។

5. **តើចំណុចអ្វីខ្លះគួរតែសរសេរបញ្ចូលនៅក្នុងសំណើសុំការលើកលែងនេះ?**

ពាក្យសុំការលើកលែង ដែលមាននៅទីនេះ មានព័ត៌មានលម្អិតបន្ថែមអំពីព័ត៌មានដែលត្រូវដាក់ទៅក្នុងសំណើសុំការលើកលែងនេះ។

**6. តើត្រូវចំណាយពេលយូរប៉ុនណា ដើម្បីទទួលបានការសម្រេចចិត្តលើពាក្យសុំការលើកលែងដែលបានដាក់ជូន?**

DCED បានទទួលនូវសំណើសុំការលើកលែងជាច្រើន ហើយកំពុងដំណើរការពិនិត្យពាក្យទាំងនោះយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

**7. បើអាជីវកម្មត្រូវបានចាត់ថ្នាក់ជាអាជីវកម្មមិនមែនប្រភេទទ្រទ្រង់ជីវិត ប៉ុន្តែមានសមត្ថភាពធ្វើប្រតិបត្តិការពីចម្ងាយ តើអាជីវកម្មនោះត្រូវបិទដែរឬអត់?**

ទេ។ អាជីវកម្មមិនមែនប្រភេទទ្រទ្រង់ជីវិតអាចបន្តប្រតិបត្តិការពីចម្ងាយតាមរយៈការធ្វើការពីចម្ងាយ ហើយក្នុងការធ្វើដូច្នេះត្រូវអនុវត្តតាមសេចក្តីណែនាំអំពីការការឃ្លាតឆ្ងាយពីគ្នា និងការកាត់បន្ថយផលប៉ះពាល់នៃវីរុសកូវីដ19 ដែលផ្តល់ដោយក្រសួងសុខាភិបាលនៃរដ្ឋ Pennsylvania និង CDC ។

**8. បើអាជីវកម្មផលិតស្ថិតនៅក្នុងចំណាត់ថ្នាក់ដែលមិនត្រូវរក្សាប្រតិបត្តិការនៅទីតាំងជាក់ស្តែង ប៉ុន្តែស្ថិតនៅក្នុងដំណើរការនៃការបំប្លែងទៅជាដំណើរការផលិតកម្មដែលត្រូវបានអនុញ្ញាតឱ្យរក្សាប្រតិបត្តិការនៅទីតាំងជាក់ស្តែង ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហាវីរុសកូវីដ19 តើពួកគេគួរធ្វើអ្វីខ្លះ?**

អាជីវកម្មមិនច្បាស់លាស់ក្នុងចំណាត់ថ្នាក់ដែលអនុញ្ញាតឱ្យរក្សាប្រតិបត្តិការនៅទីតាំងជាក់ស្តែង យោងតាមបញ្ជី និងសេចក្តីណែនាំរបស់ ទីភ្នាក់ងារសន្តិសុខលើបណ្តាញអ៊ីនធឺណិត និងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធនៃក្រសួងសន្តិសុខមាតុភូមិ គួរដាក់ពាក្យសុំការលើកលែង។ ក្នុងករណីពិសេសនេះ ពិសេសនេះសូមកត់សម្គាល់នៅក្នុងសំណើសុំការលើកលែងថា ស្ថាប័ននេះកំពុងផ្ទេរប្រតិបត្តិការទៅមុខងារទ្រទ្រង់ជីវិត ហើយក្រសួងអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចនឹងទំនាក់ទំនងជាមួយអ្នកអំពីជំហានបន្ទាប់។

**9. តើអាជីវកម្មដែលតម្រូវឲ្យផ្អាកប្រតិបត្តិការនៅទីតាំងជាក់ស្តែងអាចរក្សាបុគ្គលិកសំខាន់ៗក្នុងចំនួនមានកំណត់ ដើម្បីសុវត្ថិភាព ការដំណើរការមុខងារសំខាន់ចាំបាច់ ឬដើម្បីបន្តការអនុលោមតាមលក្ខខណ្ឌបទប្បញ្ញត្តិរបស់សហព័ន្ធ រដ្ឋ ឬមូលដ្ឋានបានដែរឬទេ?**

អាជីវកម្មដែលផ្អាកប្រតិបត្តិការនៅទីតាំងជាក់ស្តែងត្រូវកំណត់ចំនួនបុគ្គលិកនៅនឹងកន្លែង ដើម្បីរក្សាមុខងារសំខាន់ចាំបាច់ ហើយក្នុងករណីទាំងអស់អនុវត្តតាមសេចក្តីណែនាំអំពីការរក្សាចម្ងាយពីគ្នា និងការកាត់បន្ថយផលប៉ះពាល់នៃវីរុសកូវីដ 19 ដែលផ្តល់ដោយក្រសួងសុខាភិបាល PA និង CDC។

**10. តើសណ្ឋាគារគួរផ្អាកប្រតិបត្តិការដោយផ្ទាល់នៅទីតាំងជាក់ស្តែងឬអត់?**

សណ្ឋាគារ និងម៉ូតែលមិនតម្រូវឱ្យផ្អាកប្រតិបត្តិការដោយផ្ទាល់នៅទីតាំងជាក់ស្តែងទេ។ ទោះយ៉ាងណា ក៏ដូចអាជីវកម្មទាំងអស់ដែរ ពួកគេត្រូវតែអនុវត្តតាមសេចក្តីណែនាំអំពីការរក្សាចម្ងាយពីគ្នា និងការកាត់បន្ថយផលប៉ះពាល់នៃវីរុសកូវីដ 19 ដែលផ្តល់ដោយក្រសួងសុខាភិបាល PA និង CDC និងធានាថាសណ្ឋាគារនេះមិនមានការជួបជុំគ្នាលើសពី 10 នាក់តាមការណែនាំរបស់ CDC។ សណ្ឋាគារនេះនឹងមិនប្រតិបត្តិការសេវាបម្រើអាហារពេលល្ងាចទេ សេវាបម្រើអាហារទាំងអស់ត្រូវតែផ្តល់ជម្រើសតែមួយគត់គឺទិញខ្ចប់ទៅផ្ទះ។

11. **អង្គភាពនយោបាយក្នុងមូលដ្ឋានមិនមានឈ្មោះនៅក្នុងបញ្ជីនេះទេ។ តើសាលាក្រុងនានាគួរបិទដែរឬទេ?**

អង្គភាពនយោបាយក្នុងមូលដ្ឋានមិនតម្រូវឱ្យផ្អាកប្រតិបត្តិការដោយផ្ទាល់នៅទីតាំងជាក់ស្តែងទេ ប៉ុន្តែគួរតែកាត់បន្ថយប្រតិបត្តិការដោយផ្ទាល់ទៅតាមវិសាលភាពដែលអាចអាចអនុវត្តទៅបាន និងគោរពតាមតាមសេចក្តីណែនាំអំពីការកាត់បន្ថយផលប៉ះពាល់នៃវីរុសកូវីដ 19 ដែលផ្តល់ដោយក្រសួងសុខាភិបាលនៃរដ្ឋ Pennsylvania និង CDC។ រាល់សេចក្តីសម្រេចចិត្តទាំងអស់គួរតែរក្សាតុល្យភាពនៃសុវត្ថិភាពសាធារណៈឱ្យបានសមស្របដោយធានាឲ្យបាននូវការបន្តផ្តល់សេវាកម្ម និងមុខងារនៃហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។

12. **តើរដ្ឋាភិបាលទីក្រុង និងរដ្ឋាភិបាលមូលដ្ឋានគួរអនុវត្តសិទ្ធិអំណាចរបស់ខ្លួនយ៉ាងដូចម្តេច ដើម្បីគាំទ្របទបញ្ជារបស់អភិបាល?**

វិស័យដែលបានកំណត់នៅក្នុងបញ្ជីឈ្មោះអាជីវកម្មប្រភេទទ្រទ្រង់ជីវិតមិនមែនបង្កើតឡើងជាបញ្ជីយកជាការបាន ឬបញ្ជីលម្អិតអំពីវិស័យហេដ្ឋា រចនាសម្ព័ន្ធសំខាន់ៗ និងមុខងារសំខាន់ដែលគួរតែបន្តក្នុងអំឡុងពេលទប់ទល់នឹងវីរុសកូវីដ19 នោះទេ។ មន្ត្រីរដ្ឋ និងមន្ត្រីមូលដ្ឋានគួរតែប្រើសុភវិនិច្ឆ័យល្អបំផុតក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន និងចេញសារាចរណែនាំ និងសេចក្តីណែនាំអំពីការអនុវត្ត។ ស្រដៀងគ្នានេះផងដែរ ដៃគូឧស្សាហកម្មហេដ្ឋារចនាសម្ព័ន្ធសំខាន់ត្រូវតែប្រើសុភវិនិច្ឆ័យល្អបំផុត ដែលទទួលបានដំណឹងពីបញ្ជី និងសេចក្តីណែនាំរបស់ DHS ដើម្បីធានាបាននូវការបន្តប្រតិបត្តិការ និងសេវាកម្មហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ រាល់ការសម្រេចចិត្តទាំងអស់បែបនេះគួរតែធ្វើឲ្យមានតុល្យភាពរវាងវិស័យ សុខាភិបាល និងសុវត្ថិភាពសាធារណៈឱ្យបានសមស្របដោយធានាឲ្យបាននូវការបន្តផ្តល់សេវាកម្ម និងមុខងារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។

13. **ក្រុមហ៊ុនសំណង់ត្រូវបានចាត់ថ្នាក់ជាអាជីវកម្មប្រភេទមិនមែនទ្រទ្រង់ជីវិត។ តើក្រុមហ៊ុនសំណង់ទាំងអស់គួរផ្អាកប្រតិបត្តិការដោយផ្ទាល់នៅទីតាំងជាក់ស្តែងដែរឬទេ? តើក្រុមហ៊ុនសំណង់អាចបន្តគម្រោងដែលទាក់ទងនឹងការជួសជុលផ្លូវថ្នល់ ការបញ្ចប់ការសង់ផ្លូវ ការកាត់បន្ថយទឹកជំនន់ជាដើមដែរឬទេ?**

សកម្មភាពសាងសង់ដែលមិនត្រូវបានអនុញ្ញាតច្បាស់លាស់ក្រោមការណែនាំរបស់ DHS គួរតែផ្អាកប្រតិបត្តិការទូទៅ ប៉ុន្តែអាចរក្សាប្រតិបត្តិការជាក់លាក់ដែលមានដែនកំណត់ ហើយចាំបាច់ដើម្បីធានាបាននូវការអនុលោមតាមលក្ខខណ្ឌបទប្បញ្ញត្តិសហព័ន្ធ រដ្ឋ ឬមូលដ្ឋាន។

14. **ប្រសិនបើអាជីវកម្មត្រូវបានផ្តល់ការលើកលែង តើអាជីវកម្មនេះអាចបង្ហាញការលើកលែងនេះដល់ទីភ្នាក់ងារអនុវត្តច្បាប់យ៉ាងដូចម្តេច?**

អាជីវកម្មដែលបានអនុម័តសម្រាប់ការលើកលែងនឹងទទួលបានការបញ្ជាក់ជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ថា អាជីវកម្មទាំងនេះអាចចែករំលែកជាមួយទីភ្នាក់ងារអនុវត្តច្បាប់ដើម្បីបញ្ជាក់ពីការអនុញ្ញាតឲ្យរក្សាប្រតិបត្តិការ។

**15.តើបទបញ្ជានេះនឹងត្រូវបានអនុវត្តយ៉ាងដូចម្ដេច? តើនឹងមានការព្រមានទេមុនមានការដាក់ពិន័យ ឬចំណាត់ការអនុវត្តតាមច្បាប់ផ្សេងទៀត?**

ការបិទអាជីវកម្មមិនមែនប្រភេទទ្រទ្រង់ជីវិត គឺជាវិធានការណ៍ដែលបានអនុវត្តដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺឆ្លងដែលមានឈ្មោះថា កូវីដ 19 ហើយត្រូវបានចេញបញ្ជាដោយអភិបាល និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ការបិទអាជីវកម្មអាចអនុវត្តទៅបានតាមរយៈការពិន័យពីបទព្រហ្មទណ្ឌក្រោមច្បាប់ស្ដីពីការគ្រប់គ្រង និងបង្ការជំងឺឆ្នាំ 1955 និងក្រមរដ្ឋបាលឆ្នាំ 1929។

នៅពេលដែលទោសបទព្រហ្មទណ្ឌផ្សេងទៀតនៅក្នុងច្បាប់ទាំងនោះក៏ដូចជាក្រមព្រហ្មទណ្ឌ និងក្រមស្ដីពីគ្រឿងស្រវឹងអាចអនុវត្តបាន ខាងក្រោមនេះគឺជាបទប្បញ្ញត្តិចូលចរមានដោយផ្ទាល់បំផុតក្នុងការអនុវត្តបទបញ្ជា៖ 71 P. S. § 1409 និង 35 P.S. § 521.20(a) ។

យើងខិតខំជានាថាការអនុវត្តបទបញ្ជានឹងមានភាពស្របគ្នានៅទូទាំងរដ្ឋ។ យើងក៏រំពឹងផងដែរថា ការដាក់ពិន័យណាមួយពីបទល្មើសបទបញ្ជានឹងជាការដាក់ពិន័យជាបន្តបន្ទាប់ដោយចាប់ផ្ដើមពីការព្រមានដល់ជនល្មើសណាមួយដែលជាប់សង្ស័យ។ លើសពីនេះទៀត ការអនុវត្តច្បាប់គួរតែផ្ដល់អាទិភាពផ្ដោតលើអាជីវកម្មដែលមានមនុស្សប្រមូលផ្ដុំគ្នា។